មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0012

# សម្ភាសន៍ជាមួយឈ្មោះ ហឿន វុទ្ធី ភេទស្រី អាយុ៤៥ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ កុមារ

មុខងារបច្ចុប្បន្នៈ មេផ្ទះ

ស្រុកកំណើតនៅភូមិដងទង ឃុំដងទង ស្រុកដងទង ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិត្រសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៣២:៤៧

១៥ទំព័រ

វុទ្ធី : យកប្រជាជនមកដាក់នៅកន្លែងនឹងសិន ពួកខ្ញុំមក ប្រពន្ធទ័ពមកមួយចំនួនតូចៗ បាននាំគ្នាឈូសឆាយនៅក្បែរត្រង់នេះ ដល់ពេលហើយពួកយើងវាយមីនទៅ បើយើងចង់បានដីត្រង់នឹង យើងទៅនៅត្រង់នឹងរាវមីនតទៅទៀតទៅ ចេះបាននៅ បង្កើតបានប៉ុននឹងៗ កាលមុនតាមនេះសុទ្ធតែមីនទាំងអស់ មីនក្រាស់ ហើយដើមឈើធំៗមកដំបូងចាញ់ណាស់ កូនខ្ញុំអាទី២ ខ្ញុំមកចាញ់បូក៤ ហើយឈាមនៅតែ៥ៗ គេដឹកខ្ញុំទៅខាវអ៊ីដាង កូនខ្ញុំកើតបាន៧ខែ ១,២គីឡូៗ កូនកើតមកហើយ បូក២ទៀត អត់ឈាមទៀតៗ ថាខ្ញុំរស់មកដល់ប៉ុននេះជីវិតកើតម្តងទៀត ចាញ់ខ្លាំងណាស់មកនៅដំបូងៗ

ធានី : នៅដំបូងឆ្នាំប៉ុន្មាន?

វុទ្ធី : ឆ្នាំ៩០ យើងមកពី៨៥មកៗ

ធានី : មកពីណាវិញ?

វុទ្ធី : មកពីជំរុំ៨៥ កាលមុនខ្មែរក្រហមមិននៅខាងនេះទេ គេទិញដីនៅជំរុំ៨៥ គេទិញដីប្រហែលជា១០០០ម៉ែត្រ៤ជ្រុងៗ ប្រពន្ធទ័ពនៅនឹង តែទ័ពមកឡើងនៅ៨៥ដីថៃនឹងៗ ដល់ពេលយើងវៃរំដោះបានមក យើងមកនៅនេះវិញៗ យើងមកនៅនឹងមកនៅឆ្នាំ៩០ ចេះតែរស់នៅ កាលនឹងគេបើកអង្គរបើកអឺឡូហ្វបធម្មតា គេជំនួយពីចិន ហើយចេះរស់នៅៗបានទល់សព្វថ្ងៃៗ

ធានី : ៨៥កន្លែងណា?

វុទ្ធី : ៨៥នឹងនៅជុំថង ទៅពីនេះទៅតិចទេទៅដល់ៗ

ធានី ៖ ខាងណាអ្នកទិញដីឲ្យ?

វុទ្ធី ៖ កាលនឹងសម័យនឹងនៅខ្មែរក្រហមនឹងទិញឲ្យ ។

ធានី ៖ ទិញដីដើម្បីឲ្យយើងនៅ?

វុទ្ធី ៖ ចាស! ដើម្បីឲ្យប្រជាជនគេនៅៗតែប្រពន្ធទេ បើយើងអត់ទាន់មានប្ដីនៅដឹកជញ្ជូន នៅតែប្រពន្ធដែលមានកូននៅនោះបាន នារីដែលមានប្ដីមក មិនដែលបានជួបមុខគ្នាទេ ៤-៥ខែម៉ាឆ្នាំ បាននៅ ។

ធានី ៖ ហើយកាលនោះបងនៅនោះ ឬក៏បងមកជាមួយគ្រួសារ?

វុទ្ធី ៖ ខ្ញុំនៅនោះ ខ្ញុំនៅជាមួយកូន ខ្ញុំមានកូនមួយហើយនៅក្នុងដីថៃមកដល់ឆ្នាំ៩០នឹង ។

ធានី ៖ មកដល់យ៉ាងម៉េចទៅ ពេលមកដល់?

វុទ្ធី ៖ ពេលមកដល់លំបាកណាស់ សុទ្ធតែមីន សុទ្ធតែអីនឹងទៅ បានយើងរស់នៅបណ្ដើរៗ កាលសម័យអ៊ុនតាក់នឹង បានធ្វើផ្លូវធ្វើមកពីនោះផង ។ សម័យយើងឥឡូវនេះ គេធ្វើផ្លូវមកពីនោះ ផ្លូវពេញទាំងអស់បានៗស្រួល ។

ធានី ៖ កាលពេលឆ្នាំ៩០ ចាញ់ម៉េច?

វុទ្ធី ៖ ចាស! ចាញ់ខ្លាំងណាស់ ។

ធានី ៖ បងមកដល់នឹង?

វុទ្ធី ៖ មកដល់នឹងបានចាញ់ទាំងអស់ ថាផាប់ ពោះធំក៏ផាប់កូនក្នុងពោះ គេទៅដេកពេទ្យជាមួយខ្ញុំពួកម៉ុំនឹងគេទៅដេក កើតកូនហើយម្ដាយស្លាប់បាត់ទៅនៅតែកូន ។ មានតែខ្ញុំទេ អាយុថ្ងៃជាងគេ បានមកវិញ ហើយឡើងស្គមនៅសល់តែ៣៦គីឡូ សក់ឡើងវែង កាត់ថៃម៉ែថៃអាគ្រុនចាញ់នឹងថៃណាស់ ។ បានមកនៅសព្វថ្ងៃនេះទៅ តកូនតចៅយើងនៅនេះទៅ កូនឡើង៦ ខ្ញុំកើតកូននៅនោះតែមួយទេ ។

ធានី ៖ ដែលថាចាញ់នោះ?

វុទ្ធី ៖ ម៉ាកូនទី២ចាញ់ កូនទី១កើតនៅ៨៥នឹង នៅកន្លែងដីថៃ ។ កាលទី២ខ្ញុំមកកើតនៅនេះចាញ់ថាទៅដេញពេទ្យខាវអ៊ីដាង អង្គការគេដឹកតាំងពីនេះទៅ យើងទៅដេកនៅជំរុំ ចេញពីជំរុំទៅខាវអ៊ីដាងទៀត ។

ធានី ៖ ទៅដល់ពេទ្យទៅ ទើបគេជួយសង្គ្រោះទាន់?

វុទ្ធី ៖ ចាស! ទើបឥឡូវនេះទេ ឈប់ចាញ់ ។ ពីមុនចាញ់ណាស់ ឈឺកូនម៉ាផ្ទះ ភ្លៀងមកទឹកលិចទឹកថ្មើលៗនេះអីទឹកនៅដឹកដើប ។

ធានី ៖ ឲ្យតែភ្លៀងទឹកលិច?

វុទ្ធី ៖ ចាស! ភ្លៀងទឹកលិចហើយ ទើបឥឡូវគេធ្វើលូន ធ្វើថ្នល់ ភ្លៀងមកវាហូរចុះអូរអស់ ពីមុនភ្លៀងប៉ុននេះមិនបាញ់ទេ ជន់លិចអស់ណាអស់ណៃ ។

ធានី ៖ ហើយអត់មានកន្លែងហូរទេបង?

វុទ្ធី ៖ កាលពីមុនអត់មានកន្លែងហូរ ទើបឥឡូវគេធ្វើថ្នល់ ធ្វើដាក់លូដាក់អី វាហូរចុះអូរចុះអី ហូរមិនទាន់វាលិចតាមថ្នល់តាមអីនឹង តែមនុស្សវាអត់អីទេ ។

ធានី ៖ មិនលិចឥឡូវទេ លិចតាំងពីបងចូលមកនៅដំបូងម៉េះ?

វុទ្ធី ៖ ចាស! លិចតាំងពីយូរមកហើយ កាលមុនឲ្យតែភ្លៀងខ្លាំងទឹកមករូវ មកពីមន្ទីរពេទ្យវិញ អណ្តែតស្ពាន អណ្តែតផុង ឲ្យតែភ្លៀងយប់យកអីទុកហើយ ។

ធានី ៖ ខាងនោះខ្ពស់ជាង ខាងយើងទាបជាង?

វុទ្ធី ៖ ទឹកវាជះមកពីនោះ ដូចថាទឹកអូរវាឡើងមក វាប្រៀបពេញខាងនោះមុន វាមិនហូរកាត់ចេះ ។ ហើយពេលពេញនោះ វាហូរខ្លាំងវាមកចេះវិញ ។

ធានី ៖ ពេលបងនៅ៩០មកវិញ អត់អីទេ យើងចេញចូលថៃបាន?

វុទ្ធី ៖ យើងធម្មតា យើងមកនៅទៅស៊ីឈ្នួលថៃ ប្តីទៅធ្វើទាហានសម័យយើងគេត្រូវគ្នានោះ សម័យសន្តិភាពឆ្នាំភ្លេចហើយ ចាំហ៊ុន សែន ដែលលោក...មករកយើង យើងដើរទៅទទួល យើងត្រូវគ្នាទាំងអស់គ្នា បានរកស៊ីរកអីធម្មតា ធ្វើចំការធ្វើស្រែធម្មតាវិញ ។

ធានី ៖ ចុះកាលមុនអត់មានរកស៊ីធ្វើស្រែ ធ្វើចំការអីទេ?

វុទ្ធី ៖ អត់ ប្តីទៅតែមុខ ប្រពន្ធទៅស៊ីឈ្នួលថៃ បានមកហូបមិនគ្រប់មិនគ្រាន់អង្ករបើក១ឲ្យហូបយើងទ្រាំៗ ។

ធានី ៖ ហើយគ្រួសារបងធ្វើអីគេ នៅមុខនឹង?

វុទ្ធី ៖ ធ្វើទាហាន ។

ធានី ៖ ទាហានខាងអី?

វុទ្ធី ៖ ខាងខ្មែរក្រហម ។

ធានី ៖ គាត់មានងារជាអីគេ?

វុទ្ធី ៖ អានឹងដូចកាលមុនគាត់សក្តិ១ ឥឡូវគាត់សក្តិ៤កន្ទះ ។

ធានី ៖ មុខងារគាត់រាល់ថ្ងៃជាអី?

វុទ្ធី ៖ គាត់វរៈព្រំដែន ។

ធានី ៖ ខាងណាវិញ?

វុទ្ធី ៖ គាត់ប្រចាំការណ៍ខាងប៉ៃលិន ។

ធានី ៖ មិនមែនប្រចាំការណ៍នៅនេះទេ?

វុទ្ធី ៖ អត់ ។

ធានី ៖ គាត់មិនសូវនៅនេះញឹកទេ?

វុទ្ធី ៖ គាត់មកផ្ទះម៉ាឆ្នាំហើយ គាត់ឈឺ អត់បានទៅ គាត់សុំច្បាប់គេមកដេកផ្ទះ ចេះតែខ្ជិលទៅៗ ។ បើថាគាត់ទៅ១-២ខែៗ គាត់មក ។

ធានី ៖ គាត់មេគេ នៅវរៈនឹង?

វុទ្ធី ៖ ដូចថាគាត់វង មេគាត់សក្តិ៥ សក្តិ៤កន្លះគាត់វង ។

ធានី ៖ គាត់ឈ្មោះអីគេ?

វុទ្ធី ៖ គាត់ឈ្មោះ ប៊ុត ប៊ុនធឿន ។

ធានី ៖ កាលពីមុនគាត់មិនទាន់ឈឺ គាត់ខស្សាហ៍ចេញចូលទៅប៉ៃលិនទៅមកៗ?

វុទ្ធី ៖ ទៅប៉ៃលិនទៅមកៗ គាត់ដឹកទាហានទៅអី ចុះគាត់នៅត្រឹមគីឡូ១៣ទៅដល់ប៉ៃលិន ។ កាលមុនគាត់នៅប៉ុន្មានស្រុក ឥឡូវគេកាត់សល់៦ស្រុកទៅដល់ប៉ៃលិន ពីត្រឹមកំរៀងទៅ ។

ធានី ៖ យើងតាមព្រំដែននេះ សុទ្ធតែមានអ្នកការពារ?

វុទ្ធី ៖ ចា៎ស! ការពារ ។

ធានី ៖ តាមការពារយើងមើលអត់ឃើញ?

វុទ្ធី ៖ យើងមើលទៅ ពួកថៃអីដើរមើលព្រំដែន ម៉ាតែគេដើរមើលម្តង គេចាប់ពីត្រឹមណាមានអូរ កន្លែងណាអត់មានអូរ គេចាក់គ្រឹះ ។

ធានី ៖ ធ្វើម៉េចយើងមើលគ្រឹះនឹងដឹងទៅ?

វុទ្ធី ៖ គ្រឹះនោះកំពស់ណានោះ អាបង្គោលព្រំគេនោះធំៗណាស់ គេដាក់អក្សរនៅនឹង ខាងនេះខ្មែរ ខាងនោះថៃ ។

ធានី ៖ គេដាក់សងខាង?

វុទ្ធី ៖ ចា៎ស!

ធានី ៖ មានទៀត?

វុទ្ធី ៖ មាន ហើយអីចឹងវាចូលដីយើង ។

ធានី ៖ បង្គោលនឹងធ្វើយូរឥឡូវ?

វុទ្ធី ៖ បង្គោលនឹងធ្វើប្រហែលយូរដែរ ពីមុនដូចថាតូច ឥឡូវគេធ្វើធំ សសរនឹងរៀងធំដែរ ។ កាលគាត់ទៅមើលនឹងប្រហែល២ឆ្នាំ គាត់ទៅមើល គាត់ដើរត្រួត ដូចថា១-២ខែ គាត់ទៅមើលម្តង មើលបង្គោលព្រំដែននឹង ។

ធានី ៖ ហ្នឹងគេត្រូវត្រួតអីចឹង?

វុទ្ធី ៖ គេឲ្យត្រួតអីចឹង គេខ្លាចយើងរំកិល ។

ធានី ៖ រំកិលម៉េចកើត ក្រែងយើងយាម?

វុទ្ធី ៖ កាលពីមុនវាអត់មានបង្គោលធំ តែឥឡូវធំវាមិនទៅណាទេ ។

ធានី ៖ កាលពេលបងមកនៅដំបូង មើលទៅម៉េចដែរ? បងថាមានមីនម៉េច? មីនមកពីណា?

វុទ្ធី ៖ ចាស! មីននឹងកាលសម័យសង្គ្រាម គេមានមីនគេដាក់ យើងខាងខ្មែរក្រហមក៏ដាក់ អាខាងយួនគេមកពីនោះក៏គេដាក់ទៅ ព្រោះមីនត្រៀបត្រាខ្សែ មានអាស្គរផង គេដើរទាក់នោះផង មានអាគោះពិល តាមនេះសុទ្ធតែខ្សែមីនហើយ ។ នេះកន្លែងនេះ បងនោះឯង គាត់មកលេងគាត់អត់ដឹង គាត់ផ្ទុះមីនកំបុតជើងសព្វថ្ងៃ ។

ធានី ៖ កន្លែងនេះទើបនឹងរាវទេ?

វុទ្ធី ៖ កាលមុនអត់ទេ នោះក្បែរខាងនោះផ្ទះខ្ញុំ មីនស្គរ ប្ដីខ្ញុំកាលនឹងមិនដឹងម៉េច គាត់ផ្ទុះមីននៅតាមនឹង គាត់អង្គត់ជើងទល់សព្វថ្ងៃ នេះទើបនឹងរាវហើយទេ ។

ធានី ៖ កន្លែងនេះទើបនឹងរាវទេ ហើយកាលមុនអត់ទេ?

វុទ្ធី ៖ កាលមុនអត់ទេ សុទ្ធតែមីន នឹងក្បែរខាងនោះផ្ទះខ្ញុំ ប្ដីខ្ញុំកាលនឹងមិនដឹងម៉េចគាត់ទៅធ្វើបន្តន់ប៉ុនៗប្រហែល១០០គ្រាប់ ដល់ហើយអង្គការយកទៅអស់ ។

ធានី ៖ មីននឹងទើបដោះពេលណាវិញ បានយើងដើរទៅណាក៏បាន?

វុទ្ធី ៖ មីនគេទើបនឹងដោះ ដែលស៊ីម៉ាក់ គេទើបមកដោះ ។

ធានី ៖ ពេលណា?

វុទ្ធី ៖ ២០០៣ ២០០៤ ២០០៥ ទើបឥឡូវនេះហើយ ។

ធានី ៖ ទើបនឹងដោះទេ?

វុទ្ធី ៖ ចាស! ទើបនឹងដោះ ។

ធានី ៖ កាលមុនយើងដោះរាវខ្លួនឯង?

វុទ្ធី ៖ កាលមុនយើងរាវខ្លួនឯង រាវបានម៉ាផ្ទុះកាលនឹងដឹងថាមីនតែយើងអត់នាំគ្នាដើរទៅ មានសុទ្ធតែព្រៃទាំងអស់ ។

ធានី ៖ ចុះយើងមានព័ទ្ធខ្សែព័ទ្ធអីចំណាំអត់?

វុទ្ធី ៖ អត់ព័ទ្ធ ប៉ុនដឹងថាមីន ដូចថាយើងដឹងថាមីន អ្នកថ្មីគ្នាមិនមក គ្នាមិនដឹងគ្នាចូលមកផ្ទុះ កាលនឹងម៉ែ(អ្នកជិតខាង)គាត់មិនទាន់មកទេ ។ ទាំងអស់នេះមិនទាន់មានផ្ទុះទេ មានផ្ទុះរុសនឹងនៅ

ណាត្រង់នឹងមួយ ផ្ទះគេនៅនោះមួយ ។ ក្រៅពីនឹងអត់មានផ្ទះទេ សុទ្ធតែព្រៃ សុទ្ធតែមីន មានតែផ្លូវដើរទៅមាត់អូរបន្តិច នឹងផ្លូវដើរទៅនេះតិច ។

ធានី : ដើរតាមផ្លូវនឹងទេ ផុតផ្លូវនឹងអត់ហ៊ានដើរទេ?

វុទ្ធី : ចាស! ថ្ងៃខ្វះអត់ហ៊ានដើរទេ ។

ធានី : ម៉េចដែរ ការរស់នៅដំបូង ការហូបចុកអី?

វុទ្ធី : យើងពិបាក ការហូបចុកវាមិនគ្រប់គ្រាន់ យើងនៅពេលនឹង យើងនៅក្រខ្វះខាត យើងមិនទាន់មាន ធ្វើស្រែមិនទាន់បានចំការ ខ្ញុំទៅស៊ីឈ្នួលគេដែរ ។

ធានី : បងទៅស៊ីឈ្នួលគេដល់ណា?

វុទ្ធី : នៅថៃ ឆ្លងម្ខាងអូរទៅ ។

ធានី : ធ្វើអីគេ?

វុទ្ធី : បេះសណ្ដែក កាច់ពោត ច្រូតស្រូវដូចយើងអីចឹង ម៉ាថ្ងៃបាន៨០-៧០បាត មិនដល់១០០ ដូចឥឡូវ ១១០ ។

ធានី : ដល់ពេលឥឡូវ?

វុទ្ធី : ឥឡូវអត់ទេ យើងហូបចុកគ្រប់គ្រាន់ ។

ធានី : បងធ្វើចំការធ្វើអីដែរ?

វុទ្ធី : អត់បានធ្វើចំការអីធ្វើ បើព្រៃសុទ្ធតែមីន គេទើបនឹងដោះបានឥឡូវនេះ ប្រហែល១០ឆ្នាំ តាំងពីគេដោះមក យើងបានធ្វើចំការ ធ្វើស្រែ ។

ធានី : បងមកចំការមានអីដែរ?

វុទ្ធី : ខ្ញុំមានតែស្រែ ខ្ញុំអត់បានធ្វើ ស្រែនៅម៉ក់ហឺននោះ តាមផ្លូវបងឯងមកនឹង ។

ធានី : ម៉ក់ហឺននៅដីយើង?

វុទ្ធី : ដីយើង ។

ធានី : ដីម៉ាឡៃ?

វុទ្ធី : ចាស! ដីម៉ាឡៃ ។

ធានី : ម៉ក់ហឺននឹងស្អីគេ?

វុទ្ធី : ម៉ក់ហឺនហួសខ្វាសាប់ទៅ ម្តុំអូរអំពិល ។

ធានី : កន្លែងនឹងជាកន្លែងស្អីគេ?

វុទ្ធី : កន្លែងនឹងជាភូមិអូរអំពិល ។

ធានី : ម៉េចហៅម៉ក់ហឺន?

វុទ្ធី ៖ អានឹងសម័យសង្គ្រាម គេហៅអីចឹង គេដាក់ឈ្មោះ ។

ធានី ៖ ចុះកន្លែងនឹងមានទំនប់ មានអីអត់?

វុទ្ធី ៖ នៅនឹងប្រហែលជាមានផ្លូវចាស់គេ អាផ្លូវឆ្នាំយូរហើយ តាំងពីមុន៨៥ មុនអីទៅទៀត កាលយើងមានផ្លូវ៥០២ ផ្លូវចាស់គេយូរហើយ ។

ធានី ៖ ផ្លូវនឹងតាំងពីគេណា?

វុទ្ធី ៖ យូរហើយ ខ្ញុំចាំអត់បាន បើខ្ញុំមិនទាន់ធំតូចៗដែរ ។

ធានី ៖ ពីណាដល់ណា?

វុទ្ធី ៖ តាំងពីនេះដល់ខ្វាវផ្សាប់ ។

ធានី ៖ តាំងពីម៉ាឡៃ?

វុទ្ធី ៖ ចា៎ស! តាំងពីម៉ាឡៃ ។

ធានី ៖ ទីរួមស្រុកម៉ាឡៃទៅដល់ខ្វាវផ្សាប់?

វុទ្ធី ៖ ចា៎ស!

ធានី ៖ ខ្វាវផ្សាប់នៅខាងណាយើងវិញ?

វុទ្ធី ៖ ខ្វាវផ្សាប់នៅនោះ ។

ធានី ៖ នៅខាងយើងទៅពីបន្ទាយមានជ័យ ឬមកពីខាងណា?

វុទ្ធី ៖ មកពីបន្ទាយមានជ័យមក មកដល់កន្លែងនឹងគេហៅខ្វាវផ្សាប់ ផ្លូវកន្លែងដើមចាន់គិរីច្រើន ហើយយើងទៅពីនេះទៅដល់ចំខ្វាវផ្សាប់ ។

ធានី ៖ ចុះផ្លូវសាស្ត្រា?

វុទ្ធី ៖ សាស្ត្រាមកពីនោះ ។

ធានី ៖ ផ្លូវចាស់គេ ឬផ្លូវថ្មីទើបនឹងធ្វើ?

វុទ្ធី ៖ ផ្លូវថ្មីទើបនឹងធ្វើ ។

ធានី ៖ កាលមុនអត់មានផ្លូវដល់នឹងទេ?

វុទ្ធី ៖ ចា៎ស!

ធានី ៖ មានត្រឹមពីខ្វាវផ្សាប់មក?

វុទ្ធី ៖ ខ្វាវផ្សាប់ទៅដល់នឹងដូចគ្នា ផ្លូវចាស់គេ ផ្លូវទៅអីចឹងដូចគ្នា ទៅដល់ប៉ៃលិនដូចគ្នា ។

ធានី ៖ ផ្លូវចាស់នឹងតាំងពីពេលណាមុនបងកើតទៀត?

វុទ្ធី ៖ ខ្ញុំកើតហើយ តែប្រហែលខ្ញុំនៅតូចៗ តែប្តីខ្ញុំទើបចាំបាន ប្តីខ្ញុំអ្នកខាងទាហាន គេដើរធ្វើការ ។

ធានី ៖ គាត់ដើរផ្លូវ គាត់ដឹងផ្លូវច្រើន?

វុទ្ធី ៖ ចា៎ស! យើងអត់សូវបានដើរ ខាងប្ដីខ្ញុំគាត់ដឹងទាំងអស់ ។

ធានី ៖ កាលនឹងបងមានស្រុកកំណើតនៅណាវិញ?

វុទ្ធី ៖ ខ្ញុំស្រុកកំណើតនៅកំពតនោះ ។

ធានី ៖ ម៉េចបានមកនៅនេះ?

វុទ្ធី ៖ ខ្ញុំមកចេះមកៗ ម៉ែគាត់នៅក្នុងសម័យនឹងដែរ ម៉ែគាត់មក ។

ធានី ៖ កើតនៅនេះ?

វុទ្ធី ៖ ខ្ញុំកើតពីស្រុកមក ។

ធានី ៖ ម៉ែបងគាត់ធ្វើអី?

វុទ្ធី ៖ កាលពីមុនគាត់ធ្វើទាហានខ្មែរក្រហម ។

ធានី ៖ ចុះសព្វថ្ងៃគាត់នៅរស់ទេ?

វុទ្ធី ៖ សព្វថ្ងៃគាត់នៅរស់ គាត់ទៅនៅស្រុក ។

ធានី ៖ គាត់ធ្វើអីដែរ?

វុទ្ធី ៖ គាត់ធ្វើស្រែ ។

ធានី ៖ ទៅនៅកំពតវិញ?

វុទ្ធី ៖ ទៅនៅខាងស្រុកពុក ខាងពោធិ៍សាត់ ។

ធានី ៖ ភូមិឃុំអីដែរ?

វុទ្ធី ៖ អីតាឡូ បឹងខ្នារ តាឡូ ។

ធានី ៖ ស្រុកកំណើតបងកើតនៅណា?

វុទ្ធី ៖ ភូមិដងទង ឃុំដងទង ស្រុកដងទង ខេត្តកំពត ។

ធានី ៖ ដែរធ្លាប់ទៅលេងស្រុកទេ?

វុទ្ធី ៖ អត់ ខ្ញុំអត់ដែលទៅផង ដែលទៅលេស្រុកយាយ ស្រុកពុកអីធ្លាប់ទៅ បើស្រុកកំណើតខ្ញុំអត់ដែលទៅទេ ។

ធានី ៖ គ្រួសារបង គាត់មកពីណាវិញ?

វុទ្ធី ៖ គាត់នៅភ្នំពេញ ។

ធានី ៖ គាត់ធ្វើទាហានយូរហើយ?

វុទ្ធី ៖ គាត់ធ្វើតាំងពីអាយុ១០ឆ្នាំ យើងសម័យនឹងគេមិនឲ្យកូនក្មេងធ្វើកងចល័តធ្វើអី តាំងពីនឹងមករហូត ។

ធានី ៖ បងដឹងថា ពេលដែលម៉ាក់បងមកៗជាមួយគាត់?

វុទ្ធី ៖ ចាស! មកជាមួយគាត់ ។

ធានី ៖ មកពីនឹងជាមួយគាត់រហូតមកដល់នេះ?

វុទ្ធី ៖ ចាស!

ធានី ៖ កាលនឹងមកដល់តាមផ្លូវម៉េចខ្លះ ហើយជិះពីណាទៅណាបានដល់នេះ?

វុទ្ធី ៖ ខ្ញុំអត់ដឹង គេដើររហូតកាលសម័យនឹង មិនយួនវៃមក យើងមិនរត់មករហូត វៃរត់មករហូត ដើរមក គ្មានអីជិះកាលសម័យនឹង ។

ធានី ៖ ដើរពីណាទៅណា?

វុទ្ធី ៖ ស្រុកនឹងមក មិនដើរឆ្លងភ្នំ២-៣ មិនដឹងឆ្លងភ្នំប៉ុន្មានសម័យនឹង យើងអត់ទាន់ធំដែរ នៅតូចដែរបេះយកមក ។

ធានី ៖ មកដឹបូងចាញ់ម៉េច?

វុទ្ធី ៖ អានឹងហួសពីសម័យដែលយួនដេញមកហើយ៧៩ ៧៩ដល់ឆ្នាំ៩០ ។

ធានី ៖ កាល៧៩មកដល់នេះភ្លាមនៅកន្លែងណា?

វុទ្ធី ៖ មកដល់នេះភ្លាម មកនៅម្តុំភូមិដូន ម៉ែខ្ញុំនិយាយ ដល់ពេលហើយយួនមកដេញ យើងរត់ទៅនៅ៨៥ៗបានីខ្ញុំធំបានប្តីបានអីការនៅ៨៥នឹងហើយ បានយើងមកនឹងទៀត ។

ធានី ៖ ត្រឡប់មកនេះវិញ?

វុទ្ធី ៖ ត្រឡប់មកនេះវិញ ។

ធានី ៖ កកើតជាភូមិៗ?

វុទ្ធី ៖ ចាស!

ធានី ៖ ម៉េចដែរការរស់នៅសម័យនឹង ហើយបងយល់ថាម៉េចដែរ?

វុទ្ធី ៖ នៅសម័យនឹងវាមិនស្រួលដូចយើងសម័យឥឡូវនេះ ដើរហើរតាមចិត្ត កាលមុនមានខ្មែរនេះខ្មែរខាងនោះម៉ាពួក ខ្មែរយើងខាងនេះផ្សេង វាមិនបានសប្បាយដូចយើង ចង់ទៅភ្នំពេញៗ ចង់ទៅណាបានស្រួលអីចឹង ។

ធានី ៖ កាលពីមុនយើងចង់ទៅណាអត់បានទេ ក្រៅពីទៅថៃ?

វុទ្ធី ៖ អត់បានទេ យើងបានតែទៅនឹង ។

ធានី ៖ បានទៅនឹង ក្រៅពីនឹងអត់អាច?

វុទ្ធី ៖ ចង់ស្រុកខ្មែរបងប្អូនម៉ែឪមករកអីអត់បានទេ អត់ឃើញទេ ។

ធានី ៖ ម៉េចអីចឹង?

វុទ្ធី : ចុះបើម៉ាខាងម្នាក់ មកទៅយួនវើ មានផ្លូវណាមក មានគេរស់នៅដូចថាខ្ញុំមានប៉ុន្មានគ្រួសារ មានតែប៉ុននឹង ។

ធានី : ហើយទៅថៃរកស៊ី?

វុទ្ធី : រកស៊ីបានតិចតួច យើងមិនដែលស្គាល់លុយម៉ឺន លុយសែន លុយលានដូចឥឡូវទេ ។ ឥឡូវចេះរកស៊ីបានរកនេះរកនោះ ចេះបានធ្វើចំការ ធ្វើស្រែអីបាន ។ កាលសម័យមុនយើងមិនដែលស្គាល់ទេលុយតែម៉ាពាន់បាតច្រើនពេកដងម្នាក់ៗ ។

ធានី : ហើយយកទៅធ្វើអីខ្លះ?

វុទ្ធី : មានលុយនឹង យើងអត់ដែលធ្វើអី យើងមិនសូវបានទិញអីសំលៀកបំពាក់ កាលនឹងគេបើកឲ្យ ។

ធានី : គេបើកឲ្យ?

វុទ្ធី : គេបើកឲ្យសព្វគ្រប់ ស្ករប៊ីចេង អង្ករ ខោខ្លី អាវទ្រនាប់ ក្រណាត់អីបើកទាំងអស់ ដែលយើងបានលុយមក យើងដឹងថាទុកទៅ កាលនឹងមាស១ជីតែ៣៥០បាត ។

ធានី : គេបានមកពីណា អ្នកណាបើក?

វុទ្ធី : កាលនឹងចិនគេជំនួយមកឲ្យយើងខាងខ្មែរក្រហម ដល់អីចឹងហើយគាត់ចិញ្ចឹមយើង ។

ធានី : ដល់ពេលណាទៅបានគេឈប់ចិញ្ចឹម?

វុទ្ធី : ដល់ពេលយើងមកត្រូវគ្នា សម័យយើងអត់មានវៃគ្នានេះ បានគេឈប់ចិញ្ចឹមយើង ។

ធានី : កាលពេលគេចិញ្ចឹម បងថាលំបាកម៉េចដែរ?

វុទ្ធី : ឲ្យអង្ករ ប៉ុនយើងវាហូបអត់គ្រាន់ទេ នឹងយើងមកនៅនេះហើយយើងហូបអត់គ្រប់កាលយើងនៅ៨៥ យើងហូបគ្រប់គ្រាន់ កូនទើបនឹងកើតក៏គេបើកឲ្យដែរ យើងនៅក្នុងដីថៃយើងហូបគ្រប់គ្រាន់ យើងមកនៅនេះអត់គ្រប់ទេ ។

ធានី : យើងបានអីហូបទៅ បើអត់គ្រប់គ្រាន់?

វុទ្ធី : អីចឹងចេះតែស៊ីឈ្នួលគេថៃថែមទៀតទៅ ។

ធានី : ផ្គួបផ្សំ?

វុទ្ធី : ប្តីទៅខាងទាហានខាងអីនឹងទៅ ។

ធានី : ដែលភ័យបារម្ភអីអត់ពីគាត់?

វុទ្ធី : ភ័យដូចតែគ្នា ប៉ុនដឹងថាម៉េច បើយើងមិនទៅមិនបាន គេចាប់ដាក់ឡាន ។ ប្អូនខ្ញុំអាមួយនេះវាខ្វាក់ វាងងឹតភ្នែក ពេលយប់ដើរវាងើបមើលទៅលើ វាងងឹតមានថ្ងៃគ្នាមើលមិនឃើញ

ហើយគ្នាអត់ទៅមកចាប់គ្នា មកតាមគ្នា តែគ្នាមិនទៅមកហៅដាក់ឡានទាល់តែបាន ។ ទាល់នេះ គ្នារត់គេចទៅដីថៃ វាទៅនៅនឹងកូនវាមានកូនមួយរហូតទាល់ត្រូវរូវគ្នាបានគេមកវិញ ។

ធានី ៖ បងឲ្យទៅ?

វុទ្ធី ៖ ទៅខ្លួនវា កាលនឹងយើងជួយមិនបានទេ ។

ធានី ៖ ជួយអត់បានទៀត?

វុទ្ធី ៖ ហឺ! អត់បានទេ ឪពុកខ្ញុំគាត់ទៅ កាលនឹងសម័យអ៊ីនតាក់ហើយ គាត់ទៅស្រុកម៉ាតិចមិនដល់កន្លះខែផង មកវិញចាប់គាត់ដាក់គុក បានយូរតិចប្តីខ្ញុំទៅធានាមកវិញ មិនអីចឹងថាយើងខ្លាំងស្អីៗណា ។

ធានី ៖ ខាងណាមកចាប់?

វុទ្ធី ៖ ខាងខ្មែរក្រហម ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ អ្នកណាគ្រប់គ្រងនៅនឹង?

វុទ្ធី ៖ កាលនឹងមិនដឹងស្អីទេ កាលប៉ុលពតវៃនឹង ខាងនឹងឯងមេបន្ទុបន្ទាប់ ។

ធានី ៖ ស្គាល់ទេ ស្គាល់ពួកគាត់?

វុទ្ធី ៖ អត់ស្គាល់ ។

ធានី ៖ អ្នកនៅរាល់ថ្ងៃក៏អត់ស្គាល់?

វុទ្ធី ៖ ផាប់អស់អីខ្លះ ។

ធានី ៖ កាចៗ?

វុទ្ធី ៖ ចា៎ស! ចាប់វៃប្រកការ៉ុង ពូប៉ិុននេះកាលគាត់នឹងគាត់មកចាប់វៃដាក់ប្រវ៉ាក់ ខ្ញុំយកបាយឲ្យពុកឃើញ ខ្ញុំអាណិត...គេចាប់វៃហៅគ្នាមកធ្វើការ គ្នាមកថៃសោះនឹង គ្នាមករកស៊ីគ្នាមកតាមផ្លូវប៉ោយប៉ែត ។ ខ្ញុំយកបាយឲ្យពុក យកបាយយកទៅច្រើនៗឲ្យគាត់ហូបដែរអាណិត ។ បានពូប៉ិុននឹងគាត់ចិត្តល្អ គាត់មាន គាត់យកលុយមកឲ្យខ្ញុំចាយ ឲ្យពូចាយ ។

ធានី ៖ ហើយគាត់នឹងខ្មែរក្រហមដែរ?

វុទ្ធី ៖ អត់ទេ ខ្មែរមកពីនោះ ។

ធានី ៖ មករកស៊ី?

វុទ្ធី ៖ មករកស៊ី ហើយដើរចូលមក គាត់ចង់មកស្មានដីថៃ ដល់ពេលមកចំដីខ្មែរគេចាប់គាត់ ។

ធានី ៖ គាត់មកពីថៃថាមកស្រុកខ្មែរវិញ?

វុទ្ធី ៖ ចា៎ស!

ធានី ៖ ដល់ពេលមកចូលប្រទ្បំ?

វុទ្ធី ៖ ចូលប្រឡូំ ទំរាំបានដល់ប៉ុននេះវេទនាណាស់ ស្លាប់និងរស់ បងប្អូនស្លាប់ចង់អស់ហើយ ចេះតែឈឺគ្រុនចាញ់ផង ណាទៅវ៉ៃគ្នា ទៅស្លាប់ផង ។

ធានី ៖ ហើយមីន?

វុទ្ធី ៖ ចា៎ស! មីនទៀត មីននៅច្រើនៗទៀត ។ ប្តីខ្ញុំលែងយូរៗទៅខ្លាច នាំរត់ទៅស្រុកខ្មែរ នាំខ្ញុំរត់ទៅភ្នំពេញជាមួយម៉ែគាត់ បានប៉ុន្មានម៉ាឆ្នាំ២ឆ្នាំ១ឆ្នាំជាង ដល់គេត្រូវរូវគ្នា បានគាត់មកវិញ ចុះបើវ៉ៃគ្នាស្លាប់ ។ ខ្ញុំទៅតាមផ្លូវថៃ ទៅដល់ប៉ោយប៉ែត មានថៃជូនមកដល់ប៉ោយប៉ែត មកដល់ម៉ៅឡានពីប៉ោយប៉ែតដល់ភ្នំពេញ ។

ធានី ៖ បងមកពីនេះទៅនោះ ចេញពីនេះទៅបាន?

វុទ្ធី ៖ ចា៎ស! ដល់ពេលគេត្រូវគ្នា ខ្ញុំមកពីនោះវិញ កាលនឹងបានម៉ាឆ្នាំជាង ។

ធានី ៖ ម៉េចបានគេវ៉ៃ?

វុទ្ធី ៖ ចុះខ្មែរយើងខាងនោះ មិនខ្មែរខាងហ៊ុន សែន ហើយយើងនេះខាងខ្មែរក្រហម គេវ៉ៃគ្នា គេដណ្តើមគ្នា ដល់ពេលត្រូវគ្នា ។

ធានី ៖ អត់ដឹងហេតុអីបានគេត្រូវគ្នា ហេតុអីបានគេវ៉ៃគ្នា?

វុទ្ធី ៖ មិនដឹងគេដណ្តើម មិនដឹងគេស្អីម៉េច ឲ្យវ៉ៃចេះទៅវ៉ៃទៅ ។

ធានី ៖ ដល់ពេលគ្រួសារបងអត់ចង់វ៉ៃ នាំបងរត់?

វុទ្ធី ៖ រត់ ។

ធានី ៖ ដល់ពេលត្រូវគ្នា គេអត់ដាក់ទារុណកម្ម វ៉ៃអីដូចមុន?

វុទ្ធី ៖ អត់ទេ កាលមុនគ្រាន់ពុកម៉ាតិច មកវិញចាប់គាត់ដាក់គុក វ៉ៃគាត់ ធ្វើបាបគាត់ ខ្ញុំគ្មានខ្លាចអាណាដាក់គុកទេ គេថាហៅពុកទៅសួរ ដល់ពេលមិនទៅសួរ យកគាត់ទៅដល់ពួកខ្ញុំទៅឃើញស្រែកយំពេញតែនឹងឯង ខ្ញុំមិនខ្លាច ។

ធានី ៖ កាលនឹងដឹងថា អ្នកណាគេចាប់គាត់ដាក់គុក?

វុទ្ធី ៖ អត់ដឹងអ្នកណាគេ ។

ធានី ៖ អត់ចាំឈ្មោះ?

វុទ្ធី ៖ ដូចថាភ្លេចដែរ យូរដែរ ។

ធានី ៖ គាត់អត់នៅភូមិយើងទៀតទេ?

វុទ្ធី ៖ អត់ទេ ពួកនឹងដឹងទៅណាអស់ហើយ ទៅស្លាប់ ។

ធានី ៖ បើគ្រួសារបងគាត់ដឹងច្រើន?

វុទ្ធី ៖ ចាស! គាត់ដឹងច្រើន ព្រោះអីគាត់ខាងនឹង ហើយយើងបាននៅផ្ទះ យើងមើលកូនចៅមិនសូវបានដើរអីចឹង ។

ធានី ៖ ខ្ញុំសុំថតរូបបានទេ?

វុទ្ធី ៖ បាន ។ កូន៦នាក់ ។ បងឯងធ្វើអង្គការអី?

ធានី ៖ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌល...(ឯកសារកម្ពុជា) គ្រាន់ចង់បានធ្វើដូចរូបថតនេះអីចឹង ប៉ុន្តែយើងមិនមែនចង់យករូបថតចាស់ទេ នេះគេប្រមូលរូបថតចាស់ៗ គេសរសេរបន្តិចបន្តួចដើម្បីដឹងពីប្រវត្តិ ។ ខ្ញុំគ្រាន់តែចង់បានរូបថតពេលណាៗ រស់នៅម៉េច លំបាកម៉េចខ្លះនៅសម័យនឹង រហូតមកដល់ឥឡូវ តើមានរឿងអីកើតឡើង?

វុទ្ធី ៖ គេចង់បានប្រវត្តិចាស់ៗ ។

ធានី ៖ ដូចថាបងរស់នៅម៉ាឡៃលំបាកម៉េចខ្លះ ដូចថាគ្រួនចាញ់ មានដាន់មីនមានអី ទំរាំមកដល់សព្វថ្ងៃបើយើងមើលពីក្រោយមិនឆាយ បើបងមានគ្រួសារមានកូនយ៉ាប់ដែរ អ្នកខ្លះគ្រុនចាញ់ ។

វុទ្ធី ៖ យកទៅដាក់សៀវភៅ អត់ដាក់ក្នុងទូរទស្សន៍ណា?

ធានី ៖ អត់ទេ ដាក់តែក្នុងសៀវភៅនឹង ទុកឲ្យក្មេងក្រោយៗមើល ដូចខ្ញុំប្រាប់បងមុនដំបូងថា អ្នកខ្លះគេថាម៉ាឡៃជាតំបន់ដាច់ស្រយាល ខ្ញុំចង់ប្រាប់គេវិញថាម៉ាឡៃមិនមែនជាតំបន់ដាច់ស្រយាលទេ ប្រជាជននៅនឹងភាគច្រើនដូចបងនិយាយអីចឹងសុទ្ធតែអ្នកមាន មិនមែនអត់មានដីធ្វើស្រែភាគតិចដែលគាត់មករកស៊ីចំណាក់ស្រុកគាត់ទើបមកនៅ ។

វុទ្ធី ៖ យកទៅប្រទេសក្រៅ?

ធានី ៖ សម្រាប់ក្មេងៗរៀនដូចពួកខ្ញុំ ឬក៏ក្មេងទៅក្រោយទៀត អានឹងយើងមើលមិនឃើញចងក្រងទុក ។ នេះខាងបរទេសជាមួយខ្មែរ ហើយយើងគ្រាន់ចង់មើលគំរូគេទៅដើម្បីខ្មែរយើងរៀនសរសេរអី ។ ពេលយើងធ្វើទៅនឹងមានជាភាសាខ្មែរ ប្រហែលជាអាចមាននៅម៉ាឡៃ ។ មិញខ្ញុំមិនបានសុំការអនុញ្ញាតិថតជាសម្លេង ព្រោះបងនិយាយជក់ពេក ខ្ញុំមិនហ៊ានកាត់ ព្រោះមានអារម្មណ៍ថាទាំងខ្ញុំដាច់សាច់រឿង ឥឡូវខ្ញុំសុំថតជាសម្លេងអត់អីទេ?

វុទ្ធី ៖ ចាស!

ធានី ៖ សុំថតរូបបងទុកប្រើប្រាស់ និងរឿងរ៉ាវដែលបងប្រាប់យកទៅសរសេរជាសៀវភៅ ក៏ដូចជាសម្រាប់អ្នកស្រាវជ្រាវក្មេងៗក្រោយរៀនបានទេ?

វុទ្ធី ៖ បាន ។

ធានី ៖ នេះរូបថតចាស់ៗខាងបរទេសស្រាវជ្រាវ ។ បងឈ្មោះអីគេ?

វុទ្ធី ៖ ខ្ញុំឈ្មោះ ហឿន វុទ្ធី ។

ធានី ៖ ឆ្នាំនឹងអាយុប៉ុន្មាន?

វុទ្ធី ៖ ខ្ញុំអាយុ៤៧ ។

ធានី ៖ ឪពុកឈ្មោះអី?

វុទ្ធី ៖ ឪពុកខ្ញុំឈ្មោះ ចេង ហៀន ។

ធានី ៖ នៅរស់?

វុទ្ធី ៖ នៅរស់ ។

ធានី ៖ នៅខាងណា?

វុទ្ធី ៖ គាត់នៅពោធិ៍សាត់ ។

ធានី ៖ ចុះម្ដាយ?

វុទ្ធី ៖ ម្ដាយខ្ញុំឈ្មោះ ព្រំ ស ។

ធានី ៖ នៅរស់ដែរ?

វុទ្ធី ៖ នៅរស់ ។

ធានី ៖ ចុះកាលពីមុនពួកគាត់ទាំងពីរមានឈ្មោះអីក្រៅពី?

វុទ្ធី ៖ គាត់ឈ្មោះនឹង ។

ធានី ៖ ហើយគ្រួសារបងឈ្មោះអីគេ?

វុទ្ធី ៖ ឈ្មោះប៊ុត ប៊ុនធឿន ។

ធានី ៖ រៀបគ្រួសារនៅឆ្នាំ?

វុទ្ធី ៖ ឆ្នាំ៨៧ ។

ធានី ៖ កូនបងមានប៉ុន្មាននាក់?

វុទ្ធី ៖ កូន៦ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វុទ្ធី ៖ ស្រី៣ ប្រុស៣ ។

ធានី ៖ សព្វថ្ងៃគ្រួសារធ្វើអីគេ?

វុទ្ធី ៖ ទាហានវរៈព្រំដែន ។

ធានី ៖ វរៈព្រំដែនរង?

វុទ្ធី ៖ រង ។

ធានី ៖ រងអីគេ ងាររគាត់?

វុទ្ធី ៖ ងាររគាត់សក្តិ៤កន្លះ មេបញ្ជាការរង វរសេនីយ៍ឯកគេ ។

ធានី ៖ នៅខាងព្រំដែន?

វុទ្ធី ៖ ចា៎ស!

ធានី ៖ បងមានអីចង់សួរ ឬចង់បន្ថែមអីទេ?

វុទ្ធី ៖ ខ្ញុំចង់សួរថា បងឯងមកពីខាងណាដែរ?

ធានី ៖ ខ្ញុំចុះមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ពួកខ្ញុំចុះមកចង់ស្រាវជ្រាវរឿងរ៉ាវជីវភាពប្រជាជនដែលគាត់រស់នៅម៉ាឡៃតាំងពីយូរមកហើយ មកដល់ឥឡូវគាត់ជួបហេតុការណ៍អីខ្លះលំបាកម៉េចខ្លះ ។

វុទ្ធី ៖ ដូចថាខ្ញុំចង់សួរមួយទៀត យកទៅអីចឹង គេមានថាយកស្អីយើងដឹងរឿងច្រើន គេមកថ្កោលទោសយើង ។

ធានី ៖ ថ្កោលទោសរឿងអី?

វុទ្ធី ៖ ខ្លាចគេថាយើងដឹងរឿងច្រើន គេមកសួរនាំដេញដោល ។

ធានី ៖ បងគិតមើលខ្ញុំសួរទាក់ទងអីខ្លះ ដែលបងមានអីខុស យើងនិយាយពីជីវិតធម្មតា ព្រោះយើងរស់នៅរាល់ថ្ងៃ យើងនិយាយពីជីវិតដែលបងរស់នៅពីសម័យនឹងលំបាកម៉េចតើ យើងអត់មានពាក់ព័ន្ធអីនឹងរឿងថ្កោលទោសយ៉ាងម៉េច អត់មានទេ ដែលបងនិយាយមិញ?

វុទ្ធី ៖ ចា៎ស!

ធានី ៖ ព្រោះយើងនិយាយពីជីវិតរបស់យើងពិតប្រាកដ ហើយអត់មានការប៉ះពាល់ដល់អ្នកណាទេ បងយល់អីចឹង ខ្ញុំសួរមិញមានប៉ះពាល់អីទេ?

វុទ្ធី ៖ ចា៎ស! អត់មានប៉ះពាល់ទេ ។

ធានី ៖ ហើយគ្រាន់ពួកខ្ញុំជាក្មេងៗមកស្រាវជ្រាវ ។ មានអីចង់សួរទៀត?

វុទ្ធី ៖ អត់មានអីចង់សួរទៀត ។

ធានី ៖ អរគុណបងច្រើន ដែលបងបានជួយរៀបរាប់រឿងច្រើន ។

វុទ្ធី ៖ ចា៎ស!

«ចប់»